ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៤៨
ចុះថ្ងៃទី២២-០៨-២០០១
សាលដីកាលេខ៖ ០៣
ចុះថ្ងៃទី០២-០១-២០០២

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១-ឯកឧត្តម... ប្រធាន
២-លោក... ចៅក្រម
៣-លោក... ចៅក្រម
៤-លោក... ចៅក្រម
៥-លោក... ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី
លោក....

តំណាងមហាអយ្យការ
លោក... ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២ ០០១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តវ៉ាពីសាលដីកាព្រហ្មទណ្ឌ លេខ៧៨ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តី

សម្រេចទាំងមូល និងរឿងព្រហ្មទណ្ឌលេខ៤៨ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០១ របស់តុលាការកំពូល។

-ជនជាប់ចោទឈ្មោះ **ទស** (ចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកក្រសួងការបរទេស ទីលំនៅមុនពេលចាប់ខ្លួន ភូមិឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ...ម្តាយឈ្មោះ...ទោសពីមុនគ្មាន ត្រូវចោទពីបទមនុស្សឃាតដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិឃុំឈើទាលស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងទី០៥-០៨-៩៩។

-មេធាវីលោក ...

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គថ** ភេទប្រុសអាយុ២៨ឆ្នាំជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ ឃុំឈើទាល ស្រុកគៀនស្វាយ ខេត្តកណ្តាល។

-មេធាវីគ្មាន

-តាមពាក្យ បណ្តឹង ចុះថ្ងៃទី៧-០៨-៩៩ របស់ឈ្មោះ **គថ,អហ,អស, កម,គថ** និង **លយ** ថា៖ នៅថ្ងៃទី០៥-០៨-៩៩ វេលាម៉ោង៧និង៣០នាទី នាងឈ្មោះ **សរ** បានចុះមកក្រោមផ្ទះចូលក្នុងបង្គន់ ពេលនោះឈ្មោះ **ទស** បានបាញ់សម្លាប់នាង **សរ** នៅក្នុងបង្គន់នោះតែម្តង។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការខេត្តកណ្តាលថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ទស** អាយុ៤៩ឆ្នាំ ពីបទមនុស្សឃាតដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិ-ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃ០៥-០៨-៩៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៥៤ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៣(ក)ចុះថ្ងៃទី២៥-០១-២០០០ របស់តុលាការខេត្តកណ្តាល ដែលបានសេចក្តីសម្រេចដូចតទៅៈ

១-ផ្តន្ទាទោសឈ្មោះ **ទស** ដាក់ពន្ធនាគារកំណត់១១ឆ្នាំ៦ខែ គិតពីថ្ងៃចាប់ខ្លួនបានថ្ងៃទី០៥-០៨-៩៩ ពីបទមនុស្សឃាតដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ប្រព្រឹត្តនៅភូមិ-ឃុំឈើទាល ស្រុកគៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៥-០៨-៩៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៣២ និង៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-វត្ថុតាងមានៈ កាំភ្លើងខ្លីកា៥៩ លេខ៨២៧៨ មួយដើមបង់ប្រកគ្រាប់ចំនួន០១ គ្រាប់កាំភ្លើង០១គ្រាប់ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ សារុងចំនួន០១ពណ៌បៃតង អាវយឺតដៃខ្លីរូបក្រពើពណ៌ផ្ទៃមេឃចំនួន០១ ត្រូវរឹបអូសរួចបំផ្លាញចោល។

៣-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងតំណាងមុខជនរងគ្រោះ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៨ ចុះថ្ងៃទី០៩-០២-២០០០ របស់ឈ្មោះ **ទស** តវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ០៣"ក" ចុះថ្ងៃទី២៥-០១-២០០០ របស់តុលាការខេត្តកណ្តាល លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ សូមក្រុមប្រឹក្សាសម្រេចចាត់របៀបអង្កេតពីឈាម ដែលប្រឡាក់សារុង។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៧៨ ចុះថ្ងៃទី២១-០៣-២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩-០២-២០០០ របស់ឈ្មោះ **ទស** ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

២-បដិសេធសាលក្រមលេខ០៣"ក" ចុះថ្ងៃទី២៥-០១-២០០០ របស់តុលាការខេត្តកណ្តាល ចោលជាអសារបង់។

៣-សម្រេចឱ្យឈ្មោះ **ទស** រួចខ្លួនពីបទធ្វើមនុស្សឃាតដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅថ្ងៃទី០៥-០៨-៩៩ ស្ថិតនៅភូមិ-ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល។

-បង្គាប់ឱ្យដោះលែងឈ្មោះ **ទស** ឱ្យមានសេរីភាពឡើងវិញ បើគ្មានដីកាឃុំខ្លួនពីបទល្មើសផ្សេងទៀត។

៤-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី១៦-០៣-២០០១ ចំពោះមុខមេធាវីជនជាប់ចោទកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី២១-០៣-២០០១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តវ៉ាសាលដីកាព្រហ្មទណ្ឌលេខ៧៨ ចុះថ្ងៃទី២១-០៣-២០០១ របស់សាលដីកាលើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី២៨-០២-២០០១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

-បានឃើញសារណាតប ចុះថ្ងៃទី១៨-០២-២០០១ របស់ជនជាប់ចោទឈ្មោះ **ទស** ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ទស** ពីបទៈមនុស្សឃាតដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់។

-ទុកជាមោឃៈសាលដីកា របស់សាលាឧទ្ធរណ៍

- បានស្តាប់សារណារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-បានស្តាប់សារណាតបរបស់ជនជាប់ចោទ ឈ្មោះ **ទស**

-បានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **គថ** បានឆ្លើយនាពេលសវនាការថា នៅពេលកើតហេតុ គឺមិនច្បាស់លាស់ទេ មិនដឹងនរណាទេ។ សូមតុលាការដោះលែងគាត់ឱ្យមានសេរីភាពឡើងវិញ ដើម្បីឱ្យគាត់ទៅធ្វើការវិញចុះ។

បានស្តាប់លោក...មេធាវីការពារជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានទាពេលសវនាការថា៖ ក្នុងរឿងនេះ ចំពោះការចោទប្រកាន់របស់ព្រះរាជអាជ្ញារបស់តុលាការ ខេត្តកណ្តាល មកលើកូនក្តីខ្ញុំ ពុំមានភស្តុតាងច្បាស់លាស់ទេ ជនរងគ្រោះ និងជនជាប់ចោទជាគូជណ្តឹងនឹងគ្នាបម្រុងនឹងរៀបការ។ជនជាប់ចោទមិនចេះប្រើកាំភ្លើងទេ។ មានសាក្សីឃើញថាមុនពេលកើតហេតុមានជនសង្ស័យ០៥នាក់ជិះម៉ូតូ២គ្រឿងកាត់មុខផ្ទះជនរងគ្រោះ។ អាវកូនក្តីខ្ញុំ ប្រឡាក់ជ័រដើមអំពិល បារាំង មិនមែនប្រឡាក់ឈាមទេ។ បទល្មើសមិនមែនបទល្មើសជាក់ស្តែង ទាំងរបាយការណ៍នគរបាល ទាំងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសុទ្ធតែជាការសង្ស័យ។ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ តាមមាត្រា៣៨នៃច្បាប់រដ្ឋធម្មនុញ្ញ។ ដូច្នេះសូមតុលាការតម្កល់សាលដីកាសាលាឧទ្ធរណ៍។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានពីមុនទៅដដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណា របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សារណារបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី២១-០៣-២០០៣ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន ដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យជនជាប់បានរួចខ្លួនពីបទចោទ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះពុំទាន់បានស៊ើបអង្កេតឱ្យបានត្រឹមត្រូវលើចំណុចដែលអគ្គព្រះរាជអាជ្ញា បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការទេ។ ដូច្នេះចំណុច៣ មាត្រា២០៩ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ សាលដីកាព្រហ្មទណ្ឌនេះ ត្រូវទុកជាមោឃៈ។

-យល់ឃើញថា ក្រោយពេលកើតហេតុភ្លាម សាក្សីបានឃើញជនជាប់ចោទ តែម្នាក់រត់ដែលមានកាន់កាំភ្លើងនៅដៃដោយមានម្រាមដៃមួយនៅក្នុងកៃ ហើយពុំទាន់មានភស្តុតាងគ្រាប់គ្រាន់មកបញ្ជាក់ថា មានជនម្នាក់ទៀតដែលជាឃាតករ បាញ់សម្លាប់ជនរងគ្រោះ។

-យល់ឃើញថា ជនជាប់ចោទបានធ្វើសារណា ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជម្រះកំបាំងមុខ ចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៧៨ ចុះថ្ងៃទី២១-០៣-២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

-ទទួលបណ្តឹងសាទុក្ខលេខ១៧ ចុះថ្ងៃទី២១-០៣-២០០១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់ ទាំងគតិច្បាប់។

-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៧៨ចុះថ្ងៃទី២១-០៣-២០០១ របស់សាលាឧទ្ធរណ៍ ទាំងមូល។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៤៨ ចុះថ្ងៃទី២២-០៨-២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះ ជាថ្មីឡើងវិញ។

៤-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែមករា ឆ្នាំ ២០០២។